លោកពូ ខឹម វាសនា ជាទីគោរព

ខ្ញុំបានស្តាប់សំលេងរបស់ពូជាងបីឆ្នាំមកហើយ ។ ខ្ញុំពិតជាយល់ច្បាស់ពីបេះដូង និង ទឹកចិត្តរបស់ពូចំពោះប្រជាជនខ្មែរ។ ពូបានបង្រៀនខ្ញុំអោយយល់ពីមេរៀនពិតរបស់ព្រះពុទ្ធ ពីការវិភាគរកហេតុផលពីប្រវត្តិសាស្ត្រ ពីច្បាប់ ពីល្បិចរបស់ក្រុមមនុស្សខូច១ចំនួន ពីក្រុមមនុស្សដែលកំពុងដើរផ្លូវខុស និង ចំនុចជាច្រើនទៀត ដែលគ្មានសាកលវិទ្យាល័យណាអាចផ្តល់ចំណេះដឹងទាំងនេះអោយខ្ញុំបានឡើយ ។ ខ្ញុំបានចាកផុតពីការខ្លាចស្លាប់ខ្ញុំបានចាកផុតពីភាពអាត្មានិយម ខ្ញុំបានយល់ពីតម្លៃរបស់មនុស្ស ខ្ញុំបានយល់ពីច្បាប់ធម្មជាតិដែលមនុស្សស្ទើរ១ប្រទេសមិនបានយល់ ។ ខ្ញុំអាចនិយាយអោយអ្នកកាន់សាសនាដ៏ទៃខ្លះយល់ពីមេរៀនពិតរបស់ព្រះពុទ្ធហើយងាកមកជឿព្រះពុទ្ធវិញ ខ្ញុំចេះធ្វើបុណ្យត្រូវទិសដៅ ខ្ញុំចេះគ្រប់គ្រងចិត្តខ្លួនឯង ។ល។

ពិតណាស់មនុស្សមួយចំនួនធំមិនទទួលស្គាល់ថាពូកំពង់តែផ្តល់ជំនួយដ៏ធំមហិមាគឺជំនួយខួក្បាលដល់មនុស្សទេ ហើយពួកគេថែមទាំងគិតថាពូជាមនុស្សបំផ្លាញសាសនា បំបែកបំបាក់ គេជួលអោយធ្វើថែមទៀត។ ក្នុងនាមខ្ញុំជាអ្នកយល់ម្នាក់ ខ្ញុំគិតថា វាជារឿងឈឺចាប់ និង អយុត្តិធម៌សម្រាប់ពូ និង ជារឿងគួរអោយអាណិតសម្រាប់ក្រុមមនុស្សទាំងនោះ។ ខ្ញុំក៏យល់ពីទឹកចិត្តរបស់ក្រុមមនុស្សទាំងនោះដែរ ព្រោះខ្ញុំធ្លាប់ជាមនុស្សស្ថិតក្នុងក្រុមនោះដែរ។ ជាទូទៅគេតែងប្រតិកម្មភ្លាមៗនៅពេលស្តាប់សម្លេងរបស់ពូលើកដំបូង ព្រោះគេមិនមានមូលដ្ឋានក្នុងការគ្រប់គ្រងអារម្មណ៍អោយហ្នឹងដើម្បីវិភាគពីសំដីពូទេ គេមានគំនិតដែលបានកប់ទុកក្នុងចិត្តរបស់គេយូរហើយ គួបផ្សំនឹងពូនិយាយត្រង់ មិនចេះ បញ្ចោគេផង ធ្វើអោយគេមិនឯកភាពនឹងគំនិតរបស់ពូ ។ បើពួកគេបានស្តាប់ពូប្រមាណពីរ រឺ បី ខែ នោះគេនឹងយល់ហើយភ្ញាក់ស្វាងក្នុងចិត្ត ។

មានរឿងច្រើនរាប់មិនអស់ដែលខ្ញុំចង់និយាយ និង ស្ងើចសរសើរពីទឹកចិត្តរបស់ពូ ។

ខ្ញុំប្តេជ្ញាថានឹងប្រឹងប្រែងស្រាវជ្រាវរកទស្សនៈល្អៗ បូកនឹងទស្សនៈដ៏អស្ចារ្យរបស់ពូហើយផ្សព្វផ្សាយដល់អ្នកដ៏ទៃអោយបានច្រើនតាមដែលអាចធ្វើទៅបាន ។

ខ្ញុំនឹងបន្ថែមចំនួនលុយចូលរួមកម្មវិធីពូ ដើម្បីអោយចលនាពូកាន់តែរីកធំទៅៗ ។

ខ្ញុំនៅជាមួយពូជានិច្ច ! សូមពូកុំបាក់ទឹកចិត្ត!

ដោយក្តីស្រលាញ់ និង គោរពអស់ពីដួងចិត្តអំពីខ្ញុំ